អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ

# **សន្និសីទសារព័ត៌មាន**

**ដោយលោកស្រី ណាវី ភីលលៃ**

**ឧត្តមស្នងការអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្ស**

*ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨*

**សន្ទរកថាថ្លែងបើក**

សួស្តី !!!

ខ្ញុំសង្ឃឹមថាបានជួបលោក លោកស្រីមុនពេលកំណត់ ប៉ុន្តែពេលនេះទើបខ្ញុំដឹងថា ក្នុងនាមជាឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស គឺជាបុគ្គលមួយរូបដែលមិនមានពេលវេលាគ្រប់គ្រាន់សំរាប់មនុស្សគ្រប់រូបនោះឡើយ ។

មុននឹងឆ្លើយសំណួររបស់លោក លោកស្រី ខ្ញុំសូមធ្វើការកត់សំគាល់ជាបឋមមួយចំនួន អំពី**ការផ្តួចផ្តើមគំនិត ស្តីពីសេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សំរាប់អ្នកជាប់ឃុំឃាំង**។

## **សារៈតានៃការផ្តួចផ្តើមគំនិតសំរាប់ការឃុំឃាំង**

ជាផ្នែកមួយនៃពិធីរំលឹកខួបលើកទី៦០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឧត្តមស្នងការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្ស សូមអំពាវនាវដល់ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ អង្គការក្រៅរដ្ឋាភិបាល និងដៃគូនានាឱ្យយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិជនដែលត្រូវបានដកហូតសេរីភាពក្នុងពន្ធនាគារ និងកន្លែងឃុំឃាំងផ្សេងៗទៀត ។

**ការផ្តួចផ្តើមគំនិតស្តីពីសេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សំរាប់អ្នកជាប់ឃុំឃាំង** ចាប់ផ្តើមនៅថ្ងៃទី៦ ខែតុលា ដោយកំណត់យករយៈពេលមួយសប្តាហ៍ពេញ ដើម្បីខិតខំព្យាយាមនិងជំរុញបញ្ហានេះឱ្យក្លាយទៅជាបញ្ហាអន្តរជាតិ ។ ទោះជាយ៉ាងណាក៏ដោយ យើងចង់ឱ្យប្រជាពលរដ្ឋទាំងអស់ ផ្តោតការយកចិត្តទុកដាក់លើបញ្ហានេះសំរាប់រយៈពេលវែង ដោយសារថាបញ្ហាជាច្រើនក្នុងនោះដែលយើងកំពុងផ្តោតការយកចិត្តទុកដាក់ គឺមានលក្ខណៈជាប្រព័ន្ធ ហើយទាមទារពេលវេលា និងកិច្ចប្រឹងប្រែងប្រកបដោយនិរន្តរភាព ដើម្បីនាំមកនូវភាពប្រសើរឡើងកាន់តែច្រើនថែមទៀត ។

មាត្រា៩ នៃ**សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស** បញ្ជាក់ក្នុងពាក្យពេចន៍សាមញ្ញនិងច្បាស់លាស់អំពីគោលការណ៍ជាមូលដ្ឋានថា : " គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមទំនើងចិត្តឡើយ "។

មាត្រា១០ ចែងអំពីសិទ្ធិជនដែលត្រូវបានចាប់ខ្លួន : " មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាពេញលេញ នៅចំពោះមុខសវនាការមួយជាសាធារណ: និងប្រកបដោយយុត្តិធម៌ ដោយតុលាការមួយឯករាជ្យ និងមិនលំអៀង ក្នុងការសំរេចពីសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងការសំរេចពីការចោទប្រកាន់គេពីបទព្រហ្មទណ្ឌ " ។

បញ្ហាជាច្រើនទាក់ទងនឹងការឃុំឃាំងមានស្ទើរតែគ្រប់ប្រទេសទាំងអស់ ទាំងប្រទេសនៅទ្វីបខាងជើង និងទ្វីបខាងត្បូង។ បញ្ហាទាំងនោះអាចមានចរិតលក្ខណៈផ្សេងៗគ្នាជាច្រើន។ វាអាចជាបញ្ហាស្នូលនៅជុំវិញច្បាប់មួយចំនួនដែលមិនអនុវត្តតាមនីតិវិធីត្រឹមត្រូវ ឬមិនបានបញ្ចូលបទបញ្ញត្តិសំខាន់ៗដែលចែងធានាការពារ ឬវាអាចស្ដែងចេញដោយច្បាប់ផ្ទាល់ អំពីការឃុំឃាំងមនុស្សជាទូទៅ ដោយបើកចំហសំរាប់ហេតុផលនយោបាយ ឬហេតុផលផ្សេងទៀត ដែលបើតាមច្បាប់អន្តរជាតិ មិនគួរត្រូវបានចាត់ទុកថាជាបទល្មើសឡើយ។ ករណីធ្ងន់ធ្ងរជាងនេះនោះគឺ វាអាចជាចំណុចផ្ដើមមួយដ៏សំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគិតទុកជាមុន មានជាអាទិ៍ ការធ្វើទារុណកម្ម និងការសំលាប់ក្រៅច្បាប់។

## ការឃុំឃាំងស្របច្បាប់ និងមិនស្របច្បាប់

មនុស្សជាច្រើន ទាំងនៅទ្វីបខាងត្បូង និងទ្វីបខាងជើង ត្រូវបានជាប់ពន្ធនាគារដោយហេតុផលត្រឹមត្រូវ។ អ្នកទាំងនោះបានប្រព្រឹត្តបទល្មើស ហើយអាចជាការគំរាមកំហែងដល់សង្គម។ ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព គឺជាបញ្ហាជាអាទិភាពមួយដែលការិយាល័យខ្ញុំអនុវត្តជាប្រចាំ។ យើងមិនជំទាស់នឹងពន្ធនាគារ និងមន្ទីរឃុំឃាំងនោះទេ - ប៉ុន្តែពន្ធនាគារ និងមន្ទីរឃុំឃាំងទាំងនោះគួរតែធ្វើឡើងសំរាប់ដាក់មនុស្សទាំងឡាយណាដែលសក្ដិសមនឹងដាក់ពន្ធនាគារ និងមន្ទីរឃុំឃាំង ស្របតាមបទដ្ឋានអន្តរជាតិទូទៅ លំអិត និងជាមូលដ្ឋាន ដែលគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

ការដាក់សម្ពាធទៅលើស្ថាប័នរដ្ឋ សភា តុលាការ និងស្ថាប័នពាក់ព័ន្ធឯទៀតឱ្យលុបបំបាត់ ឬយ៉ាងហោចណាស់ត្រូវកាត់បន្ថយការឃុំឃាំងតាមទំនើងចិត្ត និងដោយខុសច្បាប់ គឺជាគោលដៅធំមួយក្នុងចំណោមគោលដៅធំៗពីរនៃការផ្ដួចផ្ដើមគំនិតអំពីការឃុំឃាំង។

យើងចាំបាច់ត្រូវដោះស្រាយបញ្ហានេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានការប្ដេជ្ញាចិត្តខ្លាំងក្លាថែមទៀត។ មិនមានតួលេខច្បាស់លាស់នោះទេ ប៉ុន្តែចំនួនមនុស្សនៅជុំវិញពិភពលោកដែលគេជឿថា បានស្ថិតក្នុងរូបភាពជាប់ឃុំឃាំងដោយអយុត្តិធម៌ ឬដែលមិនសមស្រម ប្រហែលជាមានចំនួនរហូតដល់រាប់លាននាក់។

## លក្ខខណ្ឌនៃការឃុំឃាំង

គោលដៅធំៗដទៃទៀតនៃការផ្តួចផ្តើមគំនិតនេះ គឺការធានាឱ្យលក្ខខណ្ឌក្នុងពន្ធនាគារ និងកន្លែងឃុំឃាំងនានាមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិអប្បបរមា។ សូមបីតែឃាតករ និងអ្នករំលោភសេពសន្ថវៈក៏នៅមានសិទ្ធិមនុស្សមូលដ្ឋានរបស់ខ្លួន រួចផុតពីការធ្វើទារុណកម្ម ការបង្អត់អាហារ ឬការប្រព្រឹត្តដូចសត្វធាតុដែរ។ ពួកគេគប្បីត្រូវបានផ្តន្ទាទោសចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ដោយការដកហូតសេរីភាពសំរាប់រយៈពេលមួយមានកំណត់ ស្របតាមច្បាប់ ប៉ុន្តែមិនត្រូវដកហូតភាពជាមនុស្សរបស់ពួកគេឡើយ។

ចំនួនច្រើនលើសលុបនៃជនពិការ និងចំនួនច្រើនលើសលុបនៃជនអន្តោប្រវេសន្ត ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន មិនមែនជាឧក្រិដ្ឋជននោះទេ ដូច្នេះហើយមិនគួរដាក់បង្ខាំងពួកគេដូចជាឧក្រិដ្ឋជនឡើយ។

អាជ្ញាធរពន្ធនាគារមិនគួរធ្វើព្រងើយកន្តើយឡើយ ប្រសិនជាមានស្ត្រី ឬបុរសណាម្នាក់មានបញ្ហា ដូចជា គាត់ត្រូវគេរំលោភផ្លូវភេទ ឬត្រូវគេវាយដំលើរាងកាយក្នុងពន្ធនាគារ។ គួរតែអនុវត្តជាប្រចាំនូវវិធានការការពារជាក់ស្តែងមួយចំនួន ដូចជា ការដាក់អ្នកទោសបុរសឱ្យនៅដាច់ដោយឡែកពីអ្នកទោសស្ត្រី។ កុមារដែលបានប្រព្រឹត្តបទល្មើស ទោះជាបទល្មើសនោះធ្ងន់ធ្ងរប៉ុនណាក៏ដោយ មិនគួរដាក់បង្ខាំងពួកគេក្នុងពន្ធនាគារជាមួយអ្នកទោសជានីតិជនដែលមិនមែនជាសាច់ញាតិបងប្អូនឡើយ។ ប្រសិនជាមានអ្នកទោសឈឺ អ្នកទោសទាំងនោះត្រូវទទួលបានការពិនិត្យព្យាបាលជម្ងឺ។ មិនគួរដាក់អ្នកទោសច្រើនលើសចំណុះនៅក្នុងបន្ទប់ឃុំឃាំងដែលគ្មានសំភារៈអនាម័យសមរម្យឬ ម្ហូបអាហារគ្រប់គ្រាន់ឡើយ។

ទាំងអស់នេះគឺជាបទដ្ឋានគ្រឹះ។ ប្រសិនជាបទដ្ឋានទាំងនេះមានការរំលោភបំពាន អាជ្ញាធរពាក់ព័ន្ធគឺជាអ្នកដែលត្រូវទទួលខុសត្រូវ។ ការប្រៀនប្រដៅអ្នកដទៃអំពីសារសំខាន់នៃការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និងការអនុវត្តន៍ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនោះនឹងមិនបានល្អឡើយ ប្រសិនបើអាជ្ញាធរ ឬបុគ្គលដែលមានឥទ្ធិពល ឬអង្គភាពទាំងនោះខ្លួនឯងផ្ទាល់ គឺជាអ្នករំលោភបំពានច្បាប់តាមអំពើចិត្តនោះ។

## បញ្ហាជាសកល

រៀងរាល់ថ្ងៃ នៅជុំវិញពិភពលោក មានករណីថ្មីៗច្រើនរាប់រយដែលបុរស ស្ត្រី និងកុមារបាននឹងកំពុងត្រូវជាប់ឃុំឃាំងដែលពួកគេមិនគួរនឹងជាប់ឡើយ - ជួនកាលស្ថិតក្នុងសភាពឃោរឃៅបំផុតទៀតផង។ ទំហំនៃការខូចខាតខាងផ្លូវកាយ និងផ្លូវចិត្តរបស់គេ ក៏ដូចជារបស់គ្រួសារពួកគេ ពិបាកនឹងស្មានដល់ លុះត្រាតែលោកអ្នកបានជួបប្រទះរឿងរ៉ាវទាំងនេះដោយផ្ទាល់។ ការភ័យខ្លាច ក្តីអស់សង្ឃឹម និងការប្រមាថ ការបាត់បង់មុខរបរ ការបែកបាក់គ្រួសារ និងធ្លាក់ក្នុងភាពទុគ៌ត។ ក្នុងសតវត្សរ៍ទី២១នេះ គឺជាពេលវេលាមួយដ៏មានតម្លៃដែលយើងបានចាត់វិធានការមាន

ប្រសិទ្ធភាពថែមទៀត ដើម្បីកាត់បន្ថយការរំលោភសិទ្ធិមនុស្សដែលមានទ្រង់ទ្រាយធំ និងដែលមានការលាក់កំបាំងនេះ ។

ដូចខ្ញុំបានលើកឡើងនៅពេលនេះ បុរស ស្ត្រី និងកុមារគ្រប់ជាតិសាសន៍ និងសាសនា គ្រប់ស្រទាប់សង្គម និងគ្រប់និន្នាការនយោបាយ បាននឹងកំពុងរងទុក្ខទោសដោយអយុត្តិធម៌ ឬដោយការប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងពន្ធនាគារ ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមបញ្ហាធំៗជាច្រើននៅលើពិភពលោក ជាញឹកញាប់បំផុតគឺ អ្នកក្រីក្រជាអ្នកដែលរងគ្រោះច្រើនជាងគេបំផុត ។ ក្រុមអ្នកក្រីក្របំផុត និងអ្នកដែលគេមិនសូវគិតគូរភាគច្រើនមានទំនោរទៅរកការក្លាយជាអ្នកទោសនៅស្ទើរតែគ្រប់ប្រទេសទាំងអស់ ។ សិទ្ធិរបស់ពួកគេងាយនឹងត្រូវគេជាន់ឈ្លី ដោយសារតែអ្នកទាំងនោះគ្មានអំណាច និងគ្មានលុយកាក់សូកប៉ាក់ ឬរកមេធាវី ។

## ទម្រង់ផ្សេងទៀតនៃការឃុំឃាំង

ការឃុំឃាំងកើតមានក្នុងរូបភាពអាក្រក់ជាច្រើន : វាមិនគ្រាន់តែជាបញ្ហាចោទឡើងអំពីអ្នកជាប់ពន្ធនាគារដោយគ្មានការចោទប្រកាន់ ឬការចោទប្រកាន់ដោយប្រឌិតនោះទេ ។

- នៅប្រទេសមួយចំនួន ជនពិការត្រូវគេដាក់បង្ខាំងដោយគ្មានរយៈពេលកំណត់ និងគ្មានក្តីសង្ឃឹម ក៏ព្រោះតែពួកគេជាជនពិការ ។
- កុមារកំព្រា ឬកុមារដែលគេបោះបង់ចោល ជារឿយៗត្រូវបានគេដាក់ក្នុងគ្រឹះស្ថានដែលមានការគ្រប់គ្រងប្រហាក់ប្រហែលគ្នា ឬអាក្រក់ជាងអ្នកជាប់ពន្ធនាគារពិតប្រាកដទៅទៀត ។
- ស្ត្រីដែលត្រូវគេជួញដូរ ជាញឹកញាយត្រូវបានគេដកហូតយកឯកសារអត្តសញ្ញាណរបស់ខ្លួន ហើយត្រូវគេដាក់បង្ខាំងក្នុងផ្ទះបន ឬក្នុងនិវេសនដ្ឋានឯកជន ។ ប្រសិនបើស្ត្រីទាំងនោះរត់គេចខ្លួន ជារឿយៗនៅពេលចាប់បានស្ត្រីនោះត្រូវគេចាក់សោរបង្ខាំងឱ្យនៅក្នុងបន្ទប់ បង្ខំឱ្យបំរើពេស្យាកម្ម ឬចោទពីបទល្មើសអន្តោប្រវេសន៍ ។
- ស្ត្រីឯទៀតរងគ្រោះក្នុងរូបភាពនៃការឃុំឃាំងជាសំងាត់ ដោយការប្តូរទៅជាឈ្មោះផ្សេងៗ - ឧទាហរណ៍ និយោជកផ្តល់ប្រាក់កម្ចីឱ្យកម្មករដោយយកការប្រាក់ខ្ពស់ ហើយតម្រូវឱ្យគ្រួសារទាំងមូលនៃកម្មករនោះធ្វើការឱ្យខ្លួនដោយយកប្រាក់ឈ្នួលទាបដើម្បីសងបំណុល និងក្នុងរូបភាពជាអ្នកបំរើនៅតាមផ្ទះ ដែលភាពប្រហាក់ប្រហែលដូចគ្នាទៅនឹងទាសករ ។

ទាំងនេះជាករណីមួយចំនួនដែលងាយរងគ្រោះបំផុត ដែលយើងត្រូវតែខិតខំប្រឹងប្រែងថែមទៀតដើម្បីការពារ ។ ប៉ុន្តែជនទាំងឡាយដែលត្រូវគេដាក់ក្នុងកន្លែងលាក់កំបាំង អាចនឹងងាយទទួលរងគ្រោះដោយការរំលោភបំពាន ។

អ្នកកាសែត ក៏ដូចជាអ្នកការពារសិទ្ធិមនុស្ស សកម្មជនស៊ីវិល និងសកម្មជននយោបាយដែរ ជារឿយៗបំផុតត្រូវបាន គេឃុំខ្លួនដោយខុសច្បាប់ ដោយគ្រាន់តែពួកគេស្វែងរកការពិតអំពីទង្វើដែលមិនសមរម្យ ឬតាមដានអំពីទំនាស់នយោបាយ។ រឿងសំងាត់នៅពីក្រោយពន្ធនាគារ មិនអាចមើលឃើញឡើយ ហើយជាញឹកញាប់ ពួកគេត្រូវបានធ្វើទុក្ខបុកម្នេញ គ្រួសារត្រូវបែកបាក់ និងវិជ្ជាជីវៈត្រូវបាត់បង់ ហើយកូនពួកគេត្រូវរងការគ្រាំគ្រាផ្លូវចិត្ត។ សព្វថ្ងៃនេះមានមនុស្សជាច្រើនដូចជាលោកអ្នក និងខ្ញុំ ដែលកំពុងតែអង្គុយក្នុងគុកពាសពេញពិភពលោក ដែលមិនគួរមានវាសនាបែបនេះឡើយ។ ដូច្នេះចូរយើងប្រើប្រាស់សប្តាហ៍ស្តីពីសេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សំរាប់អ្នកជាប់ឃុំឃាំងនេះ ដើម្បីលើកកំពស់បុព្វហេតុរបស់ពួកគេ ដែលអាចបញ្ជាក់យ៉ាងច្បាស់ថាជាបុព្វហេតុរបស់យើងទាំងអស់គ្នាផងដែរ។

ចប់